ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៥៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ/បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ក្នុងការបំពេញការងារ។

**មាត្រា ២.–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការដែលបម្រើការងារក្នុងក្របខ័ណ្ឌនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា ៣.–**

ឯកសណ្ឋានពេញលក្ខណៈរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន សម្លៀកបំពាក់ មួក សញ្ញាសម្គាល់ និងសញ្ញាស័ក្តិស្នា។

## ផ្នែកទី១
## សម្លៀកបំពាក់

**មាត្រា ៤.–**

សម្លៀកបំពាក់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន អាវ ខោ សំពត់ ក្រវ៉ាត់ក ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង។

សម្លៀកបំពាក់សម្រាប់បំពេញការងារ ត្រូវបានបែងចែកជា ៣ (បី) ប្រភេទ ដូចខាងក្រោម៖

១- សម្លៀកបំពាក់ស៊ីវិល។

២- សម្លៀកបំពាក់សាហារីយែន។

៣- សម្លៀកបំពាក់ពិធី ឬពិធីការ។

**មាត្រា ៥.–**

សម្លៀកបំពាក់ស៊ីវិលរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើសម្រាប់បំពេញការងារប្រចាំថ្ងៃ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ចំពោះបុរស**

- អាវដៃវែងមានពណ៌ផ្ទៃមេឃភ្លឺស្រាល ជាប្រភេទកឧប មានប៉ូលនៅលើស្មាទាំងសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្នា និងមានហោប៉ៅសងខាងចំនួន ២ (ពីរ) ដេរចេញជាផ្នត់នៅចំកណ្តាល គ្របដោយគម្របរាងស្លឹកពោធិ៍ ប្រើឡេវថ្លា និងមានរន្ធសម្រាប់សៀតប៊ិកនៅហោប៉ៅខាងឆ្វេង
- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំនួន ៤ (បួន) ដែលហោប៉ៅខាងក្រោយចំនួន ២ (ពីរ) ដេរបង្កប់សងខាងដោយទម្រង់មាត់កាត់ ប្រើឡេវថ្លា និងហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង



គេហទំព័រ ឯកសាររដ្ឋបាលសាធារណៈ - https://t.me/oa_channel

- ខ្សែក្រវ៉ាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) ផ្នែកខាងចុងក្បាលខ្សែក្រវ៉ាត់មានកម្ពស់ប្រវែង ៤៦ (សែសិបប្រាំមួយ) មិល្លីម៉ែត្រ ផ្នែកខាងគល់មានកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ បណ្ដោយប្រវែង ៧៣ (ចិតសិបបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវ៉ាត់មានផ្នែករំលេចអក្សរ "**ពន្ធដារ**" មានប្រវែង ១៦ (ដប់ប្រាំមួយ) មិល្លីម៉ែត្រ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ ប្រភេទចងខ្សែ (ប្រភេទ Derby Style) មានកែងកម្ពស់ប្រវែង ២៥ (ម្ភៃប្រាំ) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

**២- ចំពោះនារី**

- អាវដៃវែងមានពណ៌ផ្ទៃមេឃភ្លឺស្រាល ជាប្រភេទកខុប មានប៊ូលនៅលើស្មាទាំងសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្មា និងមានហោប៉ៅសងខាងចំនួន ២ (ពីរ) ដេរចេញជាផ្នត់នៅចំកណ្ដាល គ្របដោយគម្របរាងស្លឹកពោធិ៍ និងប្រើឡេវថ្លា
- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង
- សំពត់គ្របក្បាលជង្គង់មានពណ៌ខៀវទឹកប៊ិក ចង្កេះត មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដែលដេរបង្កប់តាមថ្នេរចំហៀង ឆែកនិងប្រើខ្សែរូតពីក្រោយ
- ខ្សែក្រវ៉ាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) មានកម្ពស់ប្រវែង ២២ (ម្ភៃពីរ) មិល្លីម៉ែត្រ បណ្ដោយប្រវែង ២៨ (ម្ភៃប្រាំបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវ៉ាត់មានផ្នែករំលេចអក្សរ "**ពន្ធដារ**" មានប្រវែង ៤,៣០ (បួនក្បៀសសាមសិប) មិល្លីម៉ែត្រ
- ស្បែកជើងកែងពណ៌ខ្មៅ (ប្រភេទអេស្កាប៉ុង ឬ Block Heel Style) ដែលមានកែងកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

**មាត្រា ៦.-**

សម្លៀកបំពាក់សាហារីយែនរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើសម្រាប់ដំណើរបំពេញបេសកកម្ម ចូលរួមកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធដារ សិក្ខាសាលា សន្និសីទ សន្និបាត និងកិច្ចប្រជុំ នៅក្រសួង-ស្ថាប័ន ឬអង្គភាពនានា តាមការចាត់តាំងនិងចាំបាច់ ត្រូវបានកំណត់ ដូចខាងក្រោម៖

**១- ចំពោះបុរស**

- អាវដៃខ្លីមានពណ៌ខៀវទឹកប៊ិក ជាប្រភេទកបើក មានប៊ូលនៅលើស្មាសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្មា និងមានហោប៉ៅចំនួន ៤ (បួន) ខាងលើចំនួន ២ (ពីរ) និងខាងក្រោមចំនួន ២ (ពីរ) ដេរ

ចេញជាផ្នត់នៅចំកណ្ដាល គ្របដោយគម្របរាងស្លឹកពោធិ៍ ប្រើឡេវដូចពណ៌អាវ និងមានរន្ធសម្រាប់សៀតប៊ិកនៅហោប៉ៅខាងឆ្វេង

- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំនួន ៤ (បួន) ដែលហោប៉ៅខាងក្រោយចំនួន ២ (ពីរ) ដេរបង្កប់សងខាងដោយទម្រង់មាត់កាត់ ប្រើឡេវថ្លា និងហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង
- ខ្សែក្រវាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) ផ្នែកខាងចុងក្បាលខ្សែក្រវាត់មានកម្ពស់ប្រវែង ៤៦ (សែសិបប្រាំមួយ) មិល្លីម៉ែត្រ ផ្នែកខាងគល់មានកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ បណ្ដោយប្រវែង ៧៣ (ចិតសិបបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវាត់មានផ្នែករលេចអក្សរ "**ពន្ធដារ**" មានប្រវែង ១៦ (ដប់ប្រាំមួយ) មិល្លីម៉ែត្រ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ ប្រភេទចងខ្សែ (ប្រភេទ Derby Style) មានកែងកម្ពស់ប្រវែង ២៥ (ម្ភៃប្រាំ) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

**២- ចំពោះនារី**

- អាវដៃខ្លីមានពណ៌ខៀវទឹកប៊ិក ជាប្រភេទកបើក មានប៉ូលនៅលើស្មាសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្មា និងមានហោប៉ៅចំនួន ៤ (បួន) ខាងលើចំនួន ២ (ពីរ) និងខាងក្រោមចំនួន ២ (ពីរ)ដែលដេរចេញជាផ្នត់នៅចំកណ្ដាល គ្របដោយគម្របរាងស្លឹកពោធិ៍ និងប្រើឡេវដូចពណ៌អាវ
- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង
- សំពត់គ្របក្បាលជង្គង់មានពណ៌ខៀវទឹកប៊ិក ចង្អេះត មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដែលដេរបង្កប់តាមថ្នេរចំហៀង ឆែកនិងប្រើខ្សែរូតពីក្រោយ
- ខ្សែក្រវាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) មានកម្ពស់ប្រវែង ២២ (ម្ភៃពីរ) មិល្លីម៉ែត្រ បណ្ដោយប្រវែង ២៨ (ម្ភៃប្រាំបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវាត់មានផ្នែករលេចអក្សរ "**ពន្ធដារ**" មានប្រវែង ៤,៣០ (បួនក្បៀសសាមសិប) មិល្លីម៉ែត្រ
- ស្បែកជើងកែងពណ៌ខ្មៅ (ប្រភេទអេស្កាប៉ុង ឬ Block Heel Style) ដែលមានកែងកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

**មាត្រា ៧.-**

សម្លៀកបំពាក់វ៉ាវីស៍ ឬពិធីការរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើសម្រាប់ចូលរួមពិធីបុណ្យជាតិ និងពិធីផ្សេងៗ ត្រូវបានកំណត់ដូចខាងក្រោម៖

គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

១- ចំពោះបុរស

- អាវធំដៃវែង (ម៉ូតក្រាហ្សេជើងផ្គង) មានពណ៌ខៀវទឹកប៊ិក ជាប្រភេទកបើកស្រួច មានប៉ូលនៅលើស្មាសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្មា និងមានហោប៉ៅចំនួន ៣ (បី) ខាងលើចំនួន ១ (មួយ) ជាប្រភេទហោប៉ៅបង្កប់ ពុំមានគម្របនិងឡេវ និងហោប៉ៅខាងក្រោមចំនួន ២ (ពីរ) សងខាង ជាប្រភេទហោប៉ៅបង្កប់ គ្របដោយគម្របពីលើដោយមិនប្រើឡេវ។ នៅពីមុខអាវនេះមានឡេវចំនួន ៤ (បួន) ដោយរៀបចេញជា ២ (ពីរ) ជួរ។ ចំណែកនៅចុងម្ខាងៗនៃដៃអាវមានឡេវចំនួន ៤ (បួន) រៀបចេញជា ១ (មួយ) ជួរ ស្ទើរតែជាប់ៗគ្នា។ ចំពោះឡេវអាវមានពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) បង្កប់និមិត្តសញ្ញា (Logo) អគ្គនាយកដ្ឋានពន្ធដារ។ អាវប្រភេទនេះ ត្រូវពាក់នៅពីលើសម្លៀកបំពាក់ប្រភេទសឺមីស៍ និងប្រើក្រវ៉ាត់កពណ៌ឈាមជ្រូក
- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំនួន ៤ (បួន) ដែលហោប៉ៅខាងក្រោយចំនួន ២ (ពីរ) ដេរបង្កប់សងខាងដោយទម្រង់មាត់កាត់ ប្រើឡេវថ្លា និងហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង
- ខ្សែក្រវ៉ាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) ផ្នែកខាងចុងក្បាលខ្សែក្រវ៉ាត់មានកម្ពស់ប្រវែង ៤៦ (សែសិបប្រាំមួយ) មិល្លីម៉ែត្រ ផ្នែកខាងគល់មានកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ បណ្តោយប្រវែង ៧៣ (ចិតសិបបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវ៉ាត់មានផ្នែករំលេចអក្សរ "**ពន្ធដារ**" មានប្រវែង ១៦ (ដប់ប្រាំមួយ) មិល្លីម៉ែត្រ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ ប្រភេទចងខ្សែ (ប្រភេទ Derby Style) មានកែងកម្ពស់ប្រវែង ២៥ (ម្ភៃប្រាំ) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

២- ចំពោះនារី

- អាវធំដៃវែង (ម៉ូតក្រាហ្សេជើងផ្គង) មានពណ៌ខៀវទឹកប៊ិក ជាប្រភេទកបើកស្រួច មានប៉ូលនៅលើស្មាសងខាងសម្រាប់ពាក់សញ្ញាស័ក្តិស្មា និងមានហោប៉ៅចំនួន ៣ (បី) ខាងលើចំនួន ១ (មួយ) ជាប្រភេទហោប៉ៅបង្កប់ ពុំមានគម្របនិងឡេវ និងហោប៉ៅខាងក្រោមចំនួន ២ (ពីរ) សងខាង ជាប្រភេទហោប៉ៅបង្កប់ គ្របដោយគម្របពីលើដោយមិនប្រើឡេវ។ នៅពីមុខអាវនេះមានឡេវចំនួន ៤ (បួន) ដោយរៀបចេញជា ២ (ពីរ) ជួរ។ ចំណែកនៅចុងម្ខាងៗនៃដៃអាវមានឡេវចំនួន ៤ (បួន) រៀបចេញជា ១ (មួយ) ជួរ ស្ទើរតែជាប់ៗគ្នា។ ចំពោះឡេវអាវមានពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) បង្កប់

និមិត្តសញ្ញា (Logo) អគ្គនាយកដ្ឋានពន្ធដារ។ អាវប្រភេទនេះ ត្រូវពាក់នៅពីលើសម្លៀកបំពាក់ប្រភេទសឺមីស៍ និងប្រើក្រវាត់កពណ៌ឈាមជ្រូក

- ខោជើងវែងមានពណ៌ខៀវទឹកប៊ិក មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដេរបង្កប់តាមថ្នេរចំហៀង
- សំពត់គ្របក្បាលជង្គង់មានពណ៌ខៀវទឹកប៊ិក ចង្កេះត មានហោប៉ៅចំហៀងសងខាងចំនួន ២ (ពីរ) ដែលដេរបង្កប់តាមថ្នេរចំហៀង ឆែកនិងប្រើខ្សែរូតពីក្រោយ
- ខ្សែក្រវាត់ធ្វើពីស្បែកពណ៌ខ្មៅ ដែលមានក្បាលខ្សែក្រវាត់ធ្វើពីលោហធាតុពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី) មានកម្ពស់ប្រវែង ២២ (ម្ភៃពីរ) មិល្លីម៉ែត្រ បណ្តោយប្រវែង ២៨ (ម្ភៃប្រាំបី) មិល្លីម៉ែត្រ និងនៅលើក្បាលខ្សែក្រវាត់មានផ្នែករំលេចអក្សរ "**ពន្ធដារ**" មានប្រវែង ៤,៣០ (បួនក្បៀសសាមសិប) មិល្លីម៉ែត្រ
- ស្បែកជើងកែងពណ៌ខ្មៅ (ប្រភេទអេស្កាប៉ុង ឬ Block Heel Style) ដែលមានកែងកម្ពស់ប្រវែង ៤០ (សែសិប) មិល្លីម៉ែត្រ
- ស្រោមជើងពណ៌ខ្មៅ។

គំរូសម្លៀកបំពាក់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## មួក

**មាត្រា ៨.—**

មួករបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាន ២ (ពីរ) ប្រភេទ គឺ មួកធំ (មួកកាស្កេត) និងមួកតូច (មួកកន្ថប)។ មួកធំមានពណ៌ខៀវទឹកប៊ិកដូចពណ៌ខោឬសំពត់ មានក្បាំងនិងជើងពណ៌ខ្មៅប្រើជាមួយសម្លៀកបំពាក់សាហារីយែន ឬវ៉ារ៉េស៍ និងមួកតូចរួមទាំងក្បាំង មានពណ៌ខៀវទឹកប៊ិកដូចពណ៌ខោឬសំពត់ ប្រើជាមួយសម្លៀកបំពាក់សឺមីស៍ ឬសាហារីយែន។

ការប្រើប្រាស់មួករបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់តាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារខាងក្រោម៖

**១- អគ្គនាយក**

**ក- មួកធំ**

មួកធំ មានរចនា ប៉ាក់ និងខ្សែ ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ហារដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្តាលអមដោយភ្ញីវល្លិនិងភ្ញីទេស និងជើងមួកផ្នែកខាងក្រោម មានរចនាប៉ាក់ជារូបផ្កាចន្ទន៍ចំកណ្តាលអមដោយភ្ញីផ្កា (ផ្កាដូង) និងកិបដោយខ្សែបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- ក្បាំងមួក មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្ដាលអមដោយភ្ញីវល្លិ និងភ្ញីទេស និងមានប៉ាក់វែណ្ឌចំនួន ៣ (បី) ខ្សែ។

ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ហារដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោម មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្ដាលអមដោយភ្ញីវល្លិនិងភ្ញីទេស និងរចនាប៉ាក់ជារូបផ្កាចន្ទន៍ចំកណ្ដាលអមដោយភ្ញីផ្កា (ផ្កាដូង)
- ក្បាំងមួក មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្ដាលអមដោយភ្ញីវល្លិ និងភ្ញីទេស និងមានប៉ាក់វែណ្ឌចំនួន ៣ (បី) ខ្សែ។

២- អគ្គនាយករង

ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងឡេវ ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ហារដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្ដាលអមដោយភ្ញីវល្លិនិងភ្ញីទេស និងជើងមួកផ្នែកខាងក្រោម មានរចនាប៉ាក់ជារូបផ្កាចន្ទន៍ចំកណ្ដាលអមដោយភ្ញីផ្កា (ផ្កាដូង) និងកិបដោយឡេវបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៥ (ប្រាំ) សន្លឹក និងមានប៉ាក់វែណ្ឌចំនួន ២ (ពីរ) ខ្សែ។

ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ហារដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោម មានរចនាប៉ាក់ជារូបផ្កាឈូកក្រពុំចំនួន ៣ (បី) ទង ចំកណ្ដាលអមដោយភ្ញីវល្លិនិងភ្ញីទេស និងរចនាប៉ាក់ជារូបផ្កាចន្ទន៍ចំកណ្ដាលអមដោយភ្ញីផ្កា (ផ្កាដូង)
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៥ (ប្រាំ) សន្លឹក និងមានប៉ាក់វែណ្ឌចំនួន ២ (ពីរ) ខ្សែ។

៣- ប្រធាននាយកដ្ឋាន

ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងឡេវ ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ហារដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែស្ទូតាស់ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ និងកិបដោយឡេវបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង

- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វ័ណ្ឌ ចំនួន ២ (ពីរ) ខ្សែ។

**ខ- មួកតូច**

មួកតូច មានរចនា និងប៉ាក់ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោម មានរចនាប៉ាក់ជាពងខ្សែស្ងួតាស់ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វ័ណ្ឌ ចំនួន ២ (ពីរ) ខ្សែ។

**៤- អនុប្រធាននាយកដ្ឋាន ឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ**

**ក- មួកធំ**

មួកធំ មានរចនា ប៉ាក់ និងខ្សែរ ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែស្ងួតាស់ ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ និងកិបដោយខ្សែរបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វ័ណ្ឌ ចំនួន ១ (មួយ) ខ្សែ។

**ខ- មួកតូច**

មួកតូច មានរចនា និងប៉ាក់ពណ៌មាស ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោម មានរចនាប៉ាក់ជាពងខ្សែស្ងួតាស់ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វ័ណ្ឌ ចំនួន ១ (មួយ) ខ្សែ។

**៥- ប្រធានការិយាល័យថ្នាក់កណ្តាល ឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ**

**ក- មួកធំ**

មួកធំ មានរចនា ប៉ាក់ និងខ្សែរ ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រប្រវែង និងទទឹង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែស្ងួតាស់ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ និងកិបដោយខ្សែរបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វ័ណ្ឌ ចំនួន ១ (មួយ) ខ្សែ។

**ខ- មួកតូច**

មួកតូច មានរចនា និងប៉ាក់ពណ៌ប្រាក់ ដូចខាងក្រោម៖



តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោមមានរចនាប៉ាក់ជារាងខ្សែសូតាស់ទំហំ ២០ (ម្ភៃ) មិល្លីម៉ែត្រ
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេស ៣ (បី) សន្លឹក និងមានប៉ាក់វណ្ឌចំនួន ១ (មួយ) ខ្សែ។

## ៦- អនុប្រធានការិយាល័យថ្នាក់កណ្ដាល ឬប្រធានការិយាល័យខេត្ត-ខណ្ឌ

### ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងខ្សែ ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ និងកិបដោយខ្សែបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វណ្ឌចំនួន ១ (មួយ) ខ្សែ។

### ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោមមានរចនាប៉ាក់ជារាងខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ
- ក្បាំងមួក មានរចនាប៉ាក់ជារូបភ្ញីវល្លិនិងសន្លឹកភ្ញីទេសចំនួន ៣ (បី) សន្លឹក និងមានប៉ាក់វណ្ឌចំនួន ១ (មួយ) ខ្សែ។

## ៧- អនុប្រធានការិយាល័យខេត្ត-ខណ្ឌ

### ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងខ្សែ ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ និងកិបដោយខ្សែបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក មានប៉ាក់វណ្ឌចំនួន ១ (មួយ) ខ្សែ។

### ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោមមានរចនាប៉ាក់ជារាងខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ
- ក្បាំងមួក មានប៉ាក់វណ្ឌចំនួន ១ (មួយ) ខ្សែ។

៨- មន្ត្រី

ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងខ្សែ ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានរចនាក្រងជាខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ និងកិបដោយខ្សែបង្គប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក ពុំមានប៉ាក់វល្លិ។

ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ និងផ្នែកខាងក្រោមមានរចនាប៉ាក់ជារាងខ្សែសូតាស់ទំហំ ១០ (ដប់) មិល្លីម៉ែត្រ
- ក្បាំងមួក ពុំមានប៉ាក់វល្លិ។

៩- មន្ត្រីកម្មសិក្សា

ក- មួកធំ

មួកធំ មានរចនា ប៉ាក់ និងខ្សែ ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាពីលោហធាតុជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ជើងមួក មានវល្លិពណ៌ខ្មៅ ទំហំ ១០ (ដប់) មិល្លីម៉ែត្រ និងកិបដោយខ្សែបង្គប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៅសងខាង
- ក្បាំងមួក ពុំមានប៉ាក់វល្លិ។

ខ- មួកតូច

មួកតូច មានរចនា និងប៉ាក់ពណ៌ប្រាក់ ដូចខាងក្រោម៖

- មុខមួកផ្នែកខាងលើ មានរចនាប៉ាក់ជារូបព្រះសង្ការដែលមានកម្ពស់ប្រវែង ៧៨ (ចិតសិបប្រាំបី) មិល្លីម៉ែត្រ និងទទឹងប្រវែង ៦៨ (ហុកសិបប្រាំបី) មិល្លីម៉ែត្រ
- ក្បាំងមួក ពុំមានប៉ាក់វល្លិ។

គំរូមួករបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## សញ្ញាសម្គាល់

**មាត្រា ៩.-**

សញ្ញាសម្គាល់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សញ្ញាសម្គាល់ពាក់នៅលើកអាវសងខាង ជារូបហង្ស មានកម្ពស់ប្រវែង ៣៩ (សាមសិបប្រាំបួន) មិល្លីម៉ែត្រ និងបណ្ដោយប្រវែង ៤៦ (សែសិបប្រាំមួយ) មិល្លីម៉ែត្រ ដែលធ្វើពីលោហធាតុមានពណ៌មាសឬប្រាក់ទៅតាម



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

ឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)។

២- ស្លាកសញ្ញាសម្គាល់ឈ្មោះ ពាក់នៅលើហោប៉ៅខាងស្ដាំ មានរាងចតុកោណកែងដែលមានបណ្ដោយប្រវែង ៨៩ (ប៉ែតសិបប្រាំបួន) មិល្លីម៉ែត្រ និងទទឹងប្រវែង ២៧ (ម្ភៃប្រាំពីរ) មិល្លីម៉ែត្រ ធ្វើពីបន្ទះលោហៈដែលផ្ទៃខាងក្រោយមានម្ជុលខ្ទាស់ និងផ្ទៃខាងមុខមានលាបពណ៌ខៀវទឹកប៊ិក ព្រមទាំងបិទជ័រពីលើផ្ទៃខាងមុខ ដើម្បីការពារការរបកពណ៌ផ្ទៃ ស៊ុម ឈ្មោះ និងអត្តលេខ។ ស្លាកសញ្ញាសម្គាល់ឈ្មោះមានស៊ុមព័ទ្ធជុំវិញនិងបន្ទាត់ខ័ណ្ឌចែកជា ២ (ពីរ) ផ្នែក ដោយនៅផ្នែកខាងឆ្វេង មាននិមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងនៅផ្នែកខាងស្ដាំមានឈ្មោះនិងអត្តលេខ។ ផ្នែកខាងស្ដាំនៃស្លាកសញ្ញាសម្គាល់ឈ្មោះ មានសរសេរអក្សរចំនួន ៣ (បី) បន្ទាត់ ដែលបន្ទាត់ខាងលើមានគោត្តនាមនិងនាមជាអក្សរខ្មែរ ដោយប្រើពុម្ពអក្សរ "Khmer OS Muol Light" ទំហំអក្សរ ១៨ (ដប់ប្រាំបី) បន្ទាត់កណ្ដាលមានគោត្តនាមនិងនាមជាអក្សរឡាតាំងដោយប្រើពុម្ពអក្សរ "Times New Roman" ទំហំអក្សរ ១២ (ដប់ពីរ) និងបន្ទាត់ខាងក្រោមមានអត្តលេខ ដោយប្រើពុម្ពអក្សរ "Times New Roman" ទំហំអក្សរ ១២ (ដប់ពីរ)។ ស្លាកសញ្ញាសម្គាល់ដែលមានស៊ុមព័ទ្ធជុំវិញ បន្ទាត់ខ័ណ្ឌ និងអក្សរមានពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)។

គំរូសញ្ញាសម្គាល់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

## ផ្នែកទី៤
## សញ្ញាស័ក្តិស្មា

**មាត្រា ១០.-**

សញ្ញាស័ក្តិស្មារបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ពាក់លើស្មាអាវទាំងសងខាង ធ្វើឡើងពីកំណាត់កម្រ៉ាលពណ៌ខៀវទឹកប៊ិក និងមានរចនាលោហធាតុបិទពីលើដែលមានពណ៌មាសឬប្រាក់ទៅតាមឋានៈដូចមាននៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ពណ៌មាសប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងពណ៌ប្រាក់ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)។ សញ្ញាស័ក្តិស្មា មានរាងទ្រវែងចំនួន ៥ (ប្រាំ) ជ្រុង និងមានប្រវែង ១៣២ (មួយរយសាមសិបពីរ) មិល្លីម៉ែត្រ ទំហំគល់ប្រវែង ៥៧ (ហាសិបប្រាំពីរ) មិល្លីម៉ែត្រ ទំហំចុងប្រវែង ៤៥ (សែសិបប្រាំ) មិល្លីម៉ែត្រ រាងកោងជាមុំទាលនៅជ្រុងនីមួយៗ និងប្រើជាមួយគ្រប់ប្រភេទសម្លៀកបំពាក់។

ការប្រើប្រាស់សញ្ញាស័ក្តិស្មារបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ ដូចខាងក្រោម៖

**១- អគ្គនាយក**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអគ្គនាយក មានរចនាដោយលោហធាតុពណ៌មាស ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវណ្ណជាក្រឡាផ្ចត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ៣ (បី) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយ

មានក្បាច់ភ្ញីទេសបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ឌខាងក្រៅទាំង ៣ (បី) ជុំ

- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រជៀងលេខ ៩ (ប្រាំបួន) និងមានព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងរាងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានគ្រាប់លោហៈចំនួន ៤ (បួន) មានរាងមូលសំប៉ែតសម្រាប់សម្គាល់ឋានៈដែលមានបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

**២- អគ្គនាយករង**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអគ្គនាយករង មានរចនាដោយលោហធាតុពណ៌មាស ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវណ្ឌជាក្រឡាផ្ទត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ២ (ពីរ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីទេសបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ឌខាងក្រៅទាំង ២ (ពីរ) ជុំ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រជៀងលេខ ៩ (ប្រាំបួន) និងមានព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងរាងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានគ្រាប់លោហៈចំនួន ៣ (បី) មានរាងមូលសំប៉ែតសម្រាប់សម្គាល់ឋានៈដែលមានបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

**៣- ប្រធាននាយកដ្ឋាន**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈប្រធាននាយកដ្ឋាន មានរចនាដោយលោហធាតុពណ៌មាស ដូចខាងក្រោម៖

- មានបន្ទះលោហៈរំលេចដោយខ្សែវណ្ឌជាក្រឡាផ្ទត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីទេសលាយភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ឌខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រជៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងរាងជាស្នែងក្របី



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- ត្រង់ផ្នែកចុងម្ខាងទៀត មានគ្រាប់លោហៈចំនួន ២ (ពីរ) មានរាងមូលសំប៉ែតសម្រាប់សម្គាល់ឋានៈដែលមានបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

**៤- អនុប្រធាននាយកដ្ឋាន និងប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអនុប្រធាននាយកដ្ឋាន និងប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ មានរចនាដោយលោហធាតុពណ៌មាស ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវណ្ណជាក្រឡាផ្ចិតៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីទេសលាយភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ណចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុង ស្របគ្នាជាមួយខ្សែវណ្ណខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងរាងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានគ្រាប់លោហៈចំនួន ១ (មួយ) មានរាងមូលសំប៉ែតសម្រាប់សម្គាល់ឋានៈដែលមានបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

**៥- ប្រធានការិយាល័យថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈប្រធានការិយាល័យថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវណ្ណជាក្រឡាផ្ចិតៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ណចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុង ស្របគ្នាជាមួយខ្សែវណ្ណខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងរាងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានគ្រាប់លោហៈចំនួន ១ (មួយ) មានរាងមូលសំប៉ែតសម្រាប់សម្គាល់ឋានៈដែលមានបង្កប់និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

**៦- អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យខេត្ត-ខណ្ឌ**

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យខេត្ត-ខណ្ឌ មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរលេចដោយខ្សែវណ្ណជាក្រឡាផ្ដត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ណចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ណខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលស៊ប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានផ្កូតលោហៈចំនួន ២ (ពីរ) និងមានបន្ទះលោហៈរលេចដោយអក្សរ "**ពន្ធដារ**"។

## ៧- អនុប្រធានការិយាល័យខេត្ត-ខណ្ឌ

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអនុប្រធានការិយាល័យខេត្ត-ខណ្ឌ មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរលេចដោយខ្សែវណ្ណជាក្រឡាផ្ដត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ណចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ណខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលស៊ប៉ែតបង្កប់រូបព្រះសង្ការ
- ត្រង់ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ផ្នែកចុងម្ខាងទៀត មានផ្កូតលោហៈចំនួន ១ (មួយ) និងមានបន្ទះលោហៈរលេចដោយអក្សរ "**ពន្ធដារ**"។

## ៨- មន្ត្រី

សញ្ញាស័ក្តិស្មាសម្រាប់មន្ត្រី មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរលេចដោយខ្សែវណ្ណជាក្រឡាផ្ដត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវណ្ណចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវណ្ណខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលស៊ប៉ែតបង្កប់រូបព្រះសង្ការ
- ត្រង់ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ផ្នែកចុងម្ខាងទៀតមានបន្ទះលោហៈរលេចដោយអក្សរ "**ពន្ធដារ**"។



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- បន្ទះលោហៈរំលេចដោយខ្សែវ័ណ្ឌជាក្រឡាផ្ចត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវ័ណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវ័ណ្ឌខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ត្រង់ផ្នែកចុងម្ខាងទៀត មានធ្នូតលោហៈចំនួន ២ (ពីរ) និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

## ៧- អនុប្រធានការិយាល័យខេត្ត-ខណ្ឌ

សញ្ញាស័ក្តិស្មាសម្រាប់ឋានៈអនុប្រធានការិយាល័យខេត្ត-ខណ្ឌ មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវ័ណ្ឌជាក្រឡាផ្ចត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវ័ណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវ័ណ្ឌខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ត្រង់ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ផ្នែកចុងម្ខាងទៀត មានធ្នូតលោហៈចំនួន ១ (មួយ) និងមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

## ៨- មន្ត្រី

សញ្ញាស័ក្តិស្មាសម្រាប់មន្ត្រី មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- បន្ទះលោហៈរំលេចដោយខ្សែវ័ណ្ឌជាក្រឡាផ្ចត់ៗព័ទ្ធជុំវិញខាងក្រៅចំនួន ១ (មួយ) ជុំ និងមានរំលេចដោយក្បាច់ភ្ញីច័ក្កច័ន អមដោយក្បាច់ភ្ញីទេសលាយភ្ញីវល្លិនៅផ្នែកខាងក្រោម ហើយមានក្បាច់ភ្ញីវល្លិបន្តព័ទ្ធជុំវិញ រួមជាមួយខ្សែវ័ណ្ឌចំនួន ១ (មួយ) ជុំទៀតនៅខាងក្នុងស្របគ្នាជាមួយខ្សែវ័ណ្ឌខាងក្រៅ
- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ត្រង់ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រដៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ផ្នែកចុងម្ខាងទៀតមានបន្ទះលោហៈរំលេចដោយអក្សរ "**ពន្ធដារ**"។

៩- មន្ត្រីកម្មសិក្សា

សញ្ញាស័ក្តិស្មាសម្រាប់មន្ត្រីកម្មសិក្សា មានរចនាដោយលោហធាតុពណ៌ប្រាក់ ដូចខាងក្រោម៖

- ផ្នែកខាងក្នុងនៅត្រង់ផ្នែកចុងស្រួចនៃសញ្ញាស័ក្តិស្មាមានគ្រាប់លោហៈរាងមូលសំប៉ែតបង្កប់រូបព្រះសង្ការ
- ផ្នែកកណ្តាលមានពន្លឺឆព្វណ្ណរង្សី និងព្រះមកុដរាជ្យនៅពីលើសញ្ញាអូមស្រជៀងលេខ ៩ (ប្រាំបួន) និងព្រះខ័ន្ធរាជ្យទ្រពីក្រោមដោយជើងពានដែលមានក្បាច់ផ្កាចន្ទន៍អមដោយស្លឹកឈើនៅសងខាងកោងជាស្នែងក្របី
- ផ្នែកចុងម្ខាងទៀតមានបន្ទះលោហៈរលេចដោយអក្សរ "**ពន្ធដារ**"។

គំរូសញ្ញាស័ក្តិស្មារបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

## ផ្នែកទី៥
## និមិត្តសញ្ញា

**មាត្រា ១១ .-**

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់និមិត្តសញ្ញាដើម្បីបោះពុម្ពឯកសារ លិខិតស្នាមផ្សេងៗ និងនៅលើឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអត្ថន័យដូចខាងក្រោម៖

- រូបនាគទាំងពីរ ដែលស្ថិតនៅផ្នែកខាងលើអមសងខាងពន្លឺឆព្វណ្ណរង្សី ជានិមិត្តរូបរបស់ថ្នាក់ដឹកនាំប្រទេសដែលកំពុងតែគាំទ្រ និងលើកទឹកចិត្តមន្ត្រីរាជការ អ្នកជាប់ពន្ធក្នុងការគោរពប្រតិបត្តិតាមច្បាប់ស្តីពីពន្ធដារ
- ពន្លឺឆព្វណ្ណរង្សីនៅពីលើគេ តំណាងឱ្យអរិយធម៌ខ្មែរ និងបង្ហាញពីភាពរីកចម្រើននៃប្រទេសកម្ពុជា
- រូបសឹង្ហទាំងពីរ ដែលកំពុងទ្រជើងពានគឺជាកម្លាំងរបស់ប្រជាពលរដ្ឋគ្រប់រូបដែលគាំទ្រ និងគោរពច្បាប់ស្តីពីពន្ធដារ
- សៀវភៅដែលមានអក្សរ "**ច្បាប់ពន្ធដារ**" ដែលទ្រដោយជើងពានគឺតំណាងឱ្យច្បាប់ស្តីពីសារពើពន្ធ
- ក្បាច់ផ្តែរដែលស្ថិតនៅផ្នែកខាងក្រោមជើងពាន និងរូបសឹង្ហទាំងពីរគឺដើម្បីគាំទ្រ ក្បាល់នឹង។

គំរូនិមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## របបផ្គត់ផ្គង់ និងការប្រើប្រាស់ឯកសណ្ឋាន

**មាត្រា ១២ .-**

មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបាននូវរបបឯកសណ្ឋាន ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ជារៀងរាល់ឆ្នាំ តាមឋានៈរបស់មន្ត្រីរាជការម្នាក់ៗ។

**មាត្រា ១៣ .-**

មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសណ្ឋានក្នុងគោលបំណង ដូចខាងក្រោម៖



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

១- សម្លៀកបំពាក់សីមីស៍៖ ប្រើសម្រាប់បំពេញការងារប្រចាំថ្ងៃ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ។

២- សម្លៀកបំពាក់សាហារីយែន៖ ប្រើសម្រាប់ដំណើរបំពេញបេសកកម្ម ចូលរួមកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធដារ សិក្ខាសាលា សន្និសីទ សន្និបាត និងកិច្ចប្រជុំ នៅក្រសួង-ស្ថាប័ន ឬអង្គភាពណាមួយ តាមការចាត់តាំងនិងចាំបាច់។

៣- សម្លៀកបំពាក់វ៉ារីស៍ ឬពិធីការ៖ ប្រើសម្រាប់ចូលរួមពិធីបុណ្យជាតិ និងពិធីផ្សេងៗ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៤.-**

ជនណាដែលបានក្លែងឯកសណ្ឋាន ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោស តាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ១០ ខែ សីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

នៃអនុក្រឹត្យលេខ ២៥៣... អនក្រ.បក ចុះថ្ងៃទី ១០... ខែ ...តុលា.... ឆ្នាំ២០២៣

ស្តីពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## គំរូសម្លៀកបំពាក់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១- សម្លៀកបំពាក់ប្រភេទសីមីស៍ ប្រើសម្រាប់បំពេញការងារប្រចាំថ្ងៃ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ

- ចំពោះបុរស



- ចំពោះនារី



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel







២- សម្លៀកបំពាក់សាហារីយែន ប្រើសម្រាប់ដំណើរបំពេញបេសកកម្ម និងចូលរួមកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធដារ សិក្ខាសាលា សន្និសីទ សន្និបាត កិច្ចប្រជុំ នៅក្រសួង-ស្ថាប័ន ឬអង្គភាពណាមួយ តាមការចាត់តាំងនិងចាំបាច់

- ចំពោះបុរស







- ចំពោះនារី



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

៣- សម្លៀកបំពាក់វ៉ារីស៍ ឬពិធីការ ប្រើសម្រាប់ចូលរួមពិធីបុណ្យជាតិ និងពិធីផ្សេងៗ

- ចំពោះបុរស



- ចំពោះនារី





**គំរូខ្សែក្រវាត់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- ចំពោះបុរស



(ពណ៌មាស ប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ

ពណ៌ប្រាក់ ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)






តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- ចំពោះនារី





(ពណ៌មាស ប្រើចាប់ពីអគ្គនាយកដល់អនុប្រធាននាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ

ពណ៌ប្រាក់ ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬអនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)






**គំរូក្រវាត់ករបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- ចំពោះបុរស



- ចំពោះនារី



## គំរូស្បែកជើងរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ចំពោះបុរស



ស្បែកជើងបុរស ប្រភេទ Derby Style
(កែងកម្ពស់ ២៥មិល្លីម៉ែត្រ)

- ចំពោះនារី



ស្បែកជើងនារី ប្រភេទអេស្កាប៊ីង ឬ Block Heel Style
(កែងកម្ពស់ ៤០មិល្លីម៉ែត្រ)

តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

## គំរូស្បែកជើងរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ២៥៣.. អនក្រ.បក ចុះថ្ងៃទី .១០.... ខែ .សីហា.... ឆ្នាំ២០២៣

ស្តីពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# គំរូមួករបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១- មួកធំ (មួកកាស្កេត)**



អគ្គនាយក



អគ្គនាយករង



ប្រធាននាយកដ្ឋាន



អនុប្រធាននាយកដ្ឋាន ឬ
ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ



ប្រធានការិយាល័យថ្នាក់កណ្តាល ឬ
អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ



អនុប្រធានការិយាល័យថ្នាក់កណ្តាល ឬ
ប្រធានការិយាល័យខេត្ត-ខណ្ឌ



អនុប្រធានការិយាល័យខេត្ត-ខណ្ឌ



មន្ត្រី



កម្មសិក្សាការី

២- មួកតូច (មួកកន្លឹប)



អគ្គនាយក



អគ្គនាយករង



ប្រធាននាយកដ្ឋាន



អនុប្រធាននាយកដ្ឋាន ឬ
ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ



ប្រធានការិយាល័យថ្នាក់កណ្តាល ឬ
អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ



អនុប្រធានការិយាល័យថ្នាក់កណ្តាល ឬ
ប្រធានការិយាល័យខេត្ត-ខណ្ឌ



អនុប្រធានការិយាល័យខេត្ត-ខណ្ឌ



មន្ត្រី



មន្ត្រីកម្មសិក្សា

តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

**ឧបសម្ព័ន្ធទី៣**

នៃអនុក្រឹត្យលេខ .២៥៣.. អនក្រ.បក ចុះថ្ងៃទី .១០.... ខែ សីហា...... ឆ្នាំ២០២៣

ស្តីពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## គំរូសញ្ញាសម្គាល់របស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១- សញ្ញាសម្គាល់ពាក់នៅលើកអាវសេងខាង




( ពណ៌មាស ប្រើចាប់ពីអគ្គនាយកដល់អនុប្រធាន
នាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ




ពណ៌ប្រាក់ ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្តាលឬ
អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី )

២- ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រី




(ពណ៌មាស ប្រើចាប់ពីអគ្គនាយកដល់អនុប្រធាន
នាយកដ្ឋានឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ




ពណ៌ប្រាក់ ប្រើចាប់ពីប្រធានការិយាល័យថ្នាក់កណ្ដាលឬ
អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌដល់មន្ត្រី)

ភោគ្យាលោងដង - https://t.me/oa_channel

**ឧបសម្ព័ន្ធទី៤**

នៃអនុក្រឹត្យលេខ .២៥៣.... អនក្រ.បក ចុះថ្ងៃទី .១០.... ខែ .មីនា..... ឆ្នាំ២០២៣

ស្តីពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គំរូសញ្ញាស័ក្តិស្មារបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**




**អគ្គនាយក**




**អគ្គនាយករង**




**ប្រធាននាយកដ្ឋាន**




**អនុប្រធាននាយកដ្ឋាន ឬ**
**ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ**

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel




ប្រធានការិយាល័យថ្នាក់កណ្តាល ឬ
អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ




អនុប្រធានការិយាល័យថ្នាក់កណ្តាល ឬ
ប្រធានការិយាល័យខេត្ត-ខណ្ឌ




អនុប្រធានការិយាល័យខេត្ត-ខណ្ឌ




មន្ត្រី




មន្ត្រីកម្មសិក្សា


៤៥ មិល្លីម៉ែត្រ
១៣៦ មិល្លីម៉ែត្រ
ពន្ធដារ
១៥,៥ មិល្លីម៉ែត្រ
៥៧ មិល្លីម៉ែត្រ
១៦ មិល្លីម៉ែត្រ
៣០ មិល្លីម៉ែត្រ
២៣ មិល្លីម៉ែត្រ
៩ មិល្លីម៉ែត្រ

**ឧបសម្ព័ន្ធទី៥**

នៃអនុក្រឹត្យលេខ ២៥៣... អនក្រ.បក ចុះថ្ងៃទី ១០..... ខែ ..សីហា..... ឆ្នាំ២០២៣

ស្ដីពីឯកសណ្ឋានរបស់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គំរូនិមិត្តសញ្ញា ( Logo ) របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

និមិត្តសញ្ញាសម្រាប់ប្រើបោះពុម្ពលើក្បាលលិខិត ( Letterhead ) ពណ៌មាសផុស ទំហំ 3.5cm x 3.5cm

និមិត្តសញ្ញាសម្រាប់ប្រើបោះពុម្ពលើក្បាលលិខិត ( Letterhead ) ពណ៌មាសធម្មតា ទំហំ 3.5cm x 3.5cm

រៀបចំដោយ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel